# ឯកឧត្តម ចម ប្រសិទ្ធ ដឹកនាំគណៈប្រតិភូកម្ពុជាទៅចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៤២

កាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១០ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសម្រាប់កម្ពុជា និងជារដ្ឋមន្ត្រីក្រុមប្រឹក្សា សហគមន៍ សេដ្ឋកិច្ចអាស៊ាន បានដឹកនាំគណៈប្រតិភូអន្តរក្រសួងទៅ ចូលរួមកិច្ចប្រជុំ រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៤២ កិច្ចប្រជុំក្រុមប្រឹក្សា សហគមន៍សេដ្ឋកិច្ចអាស៊ានលើកទី៤ និងកិច្ចប្រជុំ ពាក់ព័ន្ធ ដែលបានប្រារព្ធធ្វើពីថ្ងៃទី ២១ ដល់ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១០ នៅទីក្រុងដាណាំង ប្រទេស វៀតណាម។

នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៤២ កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ានលើកទី ៤, កិច្ចប្រជុំរួមរវាង រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងរដ្ឋមន្ត្រីក្រុមប្រឹក្សា វិនិយោគអាស៊ាន, កិច្ចប្រជុំរួមរវាងរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងរដ្ឋមន្ត្រីក្រុមប្រឹក្សាតំបន់ពាណិជ្ជកម្មសេរីអាស៊ាន, និងកិច្ចប្រជុំ ពិគ្រោះយោបល់ជាមួយប្រទេសដៃគូ សេដ្ឋកិច្ចរបស់អាស៊ាន ដូចជា : ឥណ្ឌា, ចិន, ជប៉ុន, សាធារណរដ្ឋកូរ៉េ, សហគមន៍ អឺរ៉ុប, អូស្ត្រាលី និងណូវ៉ែលហ្សេឡង់, សហព័ន្ធរុស្ស៊ី, កិច្ចប្រជុំ រវាងរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានជាមួយរដ្ឋមន្ត្រី ប្រទេស ចិន ជប៉ុន និងសាធារណរដ្ឋកូរ៉េ (អាស៊ាន បូក៣), កិច្ចប្រជុំរដ្ឋមន្ត្រី សេដ្ឋកិច្ចអាស៊ីបូព៌ា, កិច្ចប្រជុំមេគង្គ-ជប៉ុន, កិច្ចប្រជុំរវាងរដ្ឋមន្ត្រី សេដ្ឋកិច្ចអាស៊ានជាមួយនឹងក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋ អាមេរិក, កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ច កម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម, និងកិច្ចប្រជុំរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ាន។

រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានបានកត់សំគាល់ ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន កាលពីថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១០។ រដ្ឋមន្ត្រីបានអនុម័តលើកម្មវិធីការងារ ថ្មី៧ នៃកិច្ចសម្រួលពាណិជ្ជកម្មអាស៊ាន និងបានឯកភាពទទួលយកអនុសាសន៍ សម្រាប់ប្រទេសសមាជិកនីមួយៗធ្វើការ សិក្សាស្រាវជ្រាវពីស្ថានភាពនៃកិច្ចសម្រួលពាណិជ្ជកម្ម ហើយបានចាត់ទុកថា ជាការសិក្សាស្រាវជ្រាវដំបូង ក្នុងគោលបំណង ពិនិត្យមើលពីបរិយាកាសនៃកិច្ចសម្រួលពាណិជ្ជកម្មក្នុងតំបន់អាស៊ាន នាឆ្នាំ ២០១០-២០១១។

ជាមួយគ្នានេះ រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន បានអនុម័តពីធីសារសម្រាប់អនុវត្តកញ្ចប់សន្យាសេវាកម្មទី ៨ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្ម ស្តីពីសេវាកម្មអាស៊ាន ដែលនឹងគ្រោងចុះហត្ថលេខានាកិច្ចប្រជុំកំពូលអាស៊ាន នាខែតុលា ខាងមុខនេះ។ រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ក៏បានស្វាគមន៍ការចុះហត្ថលេខាលើកញ្ចប់សន្យាសេវាកម្មទី៦ ស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន នាថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩ នៅទីក្រុងហាណូយ នាពេលកន្លងទៅ។

ដោយឡែកនាកិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ានលើកទី ៤ រដ្ឋមន្ត្រីបានពិភាក្សា និងពិនិត្យឡើងវិញពីការអនុវត្តវិធានការក្នុងផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលរួមមានវិស័យពាណិជ្ជកម្មទំនិញ សេវាកម្ម វិនិយោគ។ រដ្ឋមន្ត្រីក៏បានបញ្ជាក់ឡើងវិញពីការតាំងចិត្តរបស់ខ្លួន ដើម្បីអនុវត្តវិធានការទាំងឡាយ ក្នុងផែនការសហគមន៍សេដ្ឋកិច្ចអាស៊ានឱ្យបានទាន់ពេលវេលា សំដៅធ្វើឱ្យសម្រេចបានការធ្វើសមាហរណកម្មសេដ្ឋកិច្ច ការបង្កើតទីផ្សារ និងមូលដ្ឋានផលិតកម្មរួមគ្នា ក្នុងឆ្នាំ២០១៥។

រីឯកិច្ចពិគ្រោះយោបល់រវាងរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានជាមួយដៃគូពិគ្រោះយោបល់ រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន បានពិនិត្យឡើងវិញពីកាលានុវត្តភាពក្នុងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនីមួយៗ ហើយបានធ្វើការកត់សំគាល់ពីការធ្វើឱ្យសម្រេចបាននូវតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន, តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ និងការចូលជាធរមាននៃកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរី អាស៊ាន-អូស្ត្រាលី និងណូវ៉ែលហ្សេឡង់, ការចូលជាធរមាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-ឥណ្ឌា និងការចូលជាធរមាននៃកិច្ចព្រមព្រៀងវិនិយោគ អាស៊ាន - ចិន កាលពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០។ រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន បានសង្កត់ធ្ងន់លើសារៈសំខាន់ នៃការអនុវត្តប្រកបដោយជោគជ័យនូវពាណិជ្ជ-កម្មសេរីអាស៊ានបូកមួយ ក្នុងបុព្វបទនៃការលេចឡើងស្ថាបត្យកម្មសេដ្ឋកិច្ចតំបន់អាស៊ីខាងកើត។

រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន បានស្វាគមន៍វឌ្ឍនភាពការងាររបស់ក្រុមការងារជំនាញទាំងអស់ ដែលពិនិត្យមើលពីលទ្ធភាពបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ានបូក ៣ និងលទ្ធភាពបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ានបូក ៦ ។

ក្នុងឱកាសនោះដែរ ដោយទទួលបានសិទ្ធិប្រទានពី ***សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*** ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានចូលរួមចុះហត្ថលេខាលើពិធីសារវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-កូរ៉េ។

ការចុះហត្ថលេខាលើពិធីសារនេះ  នឹងជួយពង្រឹងដល់ការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-កូរ៉េ  ឱ្យកាន់តែប្រសើរឡើងផងដែរ ។